សំនួរលើកសួរជាញឹកញាប់
សម្រាប់មាតាបិតា ដែលទាក់ទងអំពីកម្មវិធីរៀនពីចម្ងាយ
**មកទល់ថ្ងៃទី5 ខែធ្នូ ឆ្នាំ2020**

សំនួរទាំងអស់នេះនឹងធ្វើការកែសម្រួលនៅពេលណាបានទទួលជាពត៌មានថ្មីៗ ។ ក្រសួងអប់រំ ឱស្រ្ទីត ឡុងប៊ីច (LBUSD) កំពុងបំពេញកិច្ចការជាមួយក្រសួងដៃគូក្នុងសហគមន៍ ដើម្បីដោះស្រាយមកលើបញ្ហាលំបាកៗ និង ជម្រាបជូនលោកអ្នកទាន់ពេលវេលា ។

កិច្ចការផ្នែកខាងក្រោមត្រូវបានលើកពិគ្រោះយ៉ាងក្បោះក្បាយក្នុង កិច្ចប្រជុំសហគមន៍ស្តីអំពីកម្មវិធីសិក្សា នៅថ្ងៃទី5 ខែធ្នូ ឆ្នាំ2020:

| អង់គ្លេស | | អេស្ប៉ាញ៉ូល | | ខ្មែរ | |
|---|---|---|---|---|---|
| វិដេអូ | ពត៌មានតាមទំព័រ | វិដេអូ | ពត៌មានតាមទំព័រ | វិដេអូ | ពត៌មានតាមទំព័រ |

| ការទទួលកម្មវិធីរៀនពីចម្ងាយ | |
|---|---|
| តើសិស្សមកពីក្រុមណាខ្លះ ដែលមិនសូវតែងតែបានទទួលការរៀនយ៉ាងទៀងទាត់ជាមួយកម្មវិធីរៀនពីចម្ងាយ និង តើយើងអាចធ្វើអ្វីសម្រាប់នាំមកជាភាពបង្កើនជួយបាន? | សិស្ស ដែលមិនសូវតែងតែបានទទួលការរៀនយ៉ាងទៀងទាត់ពីចម្ងាយ គឺមានការបង្ហាញទៅតាមលទ្ធផលទាក់ទងវត្តមានប្រចាំថ្ងៃនៅផ្នែកខាងក្រោម ។ ក្រសួងអប់រំ ឱស្រ្ទីត និង សាលារៀនប្រឹងប្រែងជួយបង្កើនផ្នែកវត្តមានប្រចាំថ្ងៃ និង ឱកាសសម្រាប់រៀន ដែលរាប់បញ្ចូលទាំងការទាក់ទងទៅកាន់ក្រុមគ្រួសារនិមួយៗតាមរយៈធ្វើសំបុត្រ ទូរស័ព្ទ អ៊ីម៉ែល និង ទៅពិនិត្យដល់ផ្ទះ ។ |
| ចំនួន/ចំនួនភាគរយនៃសិស្ស ដែលបានបើកចូលជាមួយកម្មវិធីរៀនពីចម្ងាយក្នុងពេលចាក់បង្ហាត់មេរៀនអោយឃើញភ្លាមៗ (ការបំបែកទៅតាមពូជសាសន៍/ជាតិពន្ធ កម្មវិធីអប់រំពិសេស ឋានៈជាសិស្សគេជ្រើសចិញ្ចឹម សិស្សរៀនភាសា អង់គ្លេស សិស្សគ្មានផ្ទះនៅ និង សិស្សមកពីភាពក្រីក្រ) | សម្រាប់កម្រិតថ្នាក់ transitional kindergarten (TK) រហូតដល់ថ្នាក់ទី 5 គឺក្រសួងអប់រំ ឱស្រ្ទីត ទទួលសិស្សចូលរៀនតាមរយៈបង្ហាត់មេរៀនបង្ហាញអោយឃើញភ្លាមៗជាចំនួន 94.8% និង ការចូលរៀនតាមរយៈចាក់បង្ហាញមេរៀនតាមក្រោយជាចំនួន 0.4% ។ សម្រាប់កម្រិតថ្នាក់ទី 6 រហូតដល់ទី 12 គឺក្រសួងអប់រំ ឱស្រ្ទីត ទទួលសិស្សចូលរៀនតាមរយៈបង្ហាត់មេរៀនបង្ហាញអោយឃើញភ្លាមៗជាចំនួន 86.9% និង ការចូលរៀនតាមរយៈចាក់បង្ហាញមេរៀនតាមក្រោយជាចំនួន 0.8% ។<br><br>ផ្នែកខាងក្រោម គឺជាតារាងបែកចែកទៅតាមក្រុមសិស្ស ។ សូមចំណាំអំពីអក្សរកាត់សម្រាប់ប្រើបង្ហាញដូចតទៅ:<br>• English Learner (EL) សិស្សរៀនភាសា អង់គ្លេស<br>• Reclassified Fluent English Proficient (RFEP) សិស្សទទួលការចាត់ទុកឡើងវិញ ដែលមានសមត្ថភាពចេះភាសា អង់គ្លេស ស្ទាត់<br>• Resource Specialist Program (RSP) កម្មវិធីផ្តល់ជំនួយពីគ្រូឯកទេស<br>• Socioeconomic Status (SES) ឋានៈជាភាពក្រីក្រ<br>• Transitional Kindergarten (TK) ថ្នាក់សម្រាប់សិស្សវ័យតូច មុនចូលថ្នាក់មត្តេយ្យ |

**ថ្នាក់ TK – 5**

| ក្រុមសិស្ស | រៀនតាមមេរៀនចាក់បង្ហាញតាមក្រោយ | រៀនតាមមេរៀនចាក់បង្ហាញភ្លាមៗ |
|---|---|---|
| សិស្សទាំងអស់ | 0.4% | 94.8% |
| សិស្សអាមេរិកាំង ខ្មៅ | 0.6% | 91.2% |
| សិស្ស អាស៊ី | 0.3% | 96.7% |
| សិស្ស ខ្មែរ | 0.4% | 96.1% |
| សិស្ស ពីលីពីនណូ | 0.3% | 98.2% |
| សិស្ស ហ៊ីស្ប៉ានិក | 0.4% | 94.5% |
| សិស្សកោះ ប៉ាស៊ីហ្វិក | 0.4% | 93.1% |
| សិស្សអាមេរិកាំង ស | 0.6% | 97.3% |
| សិស្សរៀនភាសា អង់គ្លេស | 0.4% | 93.9% |
| សិស្ស EL + RFEP | 0.3% | 94.8% |
| សិស្សគ្មានផ្ទះរស់នៅ/សិស្សគេជ្រើសចិញ្ចឹម | 0.2% | 91.7% |
| សិស្ស SES បំផុត | 0.2% | 94.6% |

**ថ្នាក់ទី 6 – 12**

| ក្រុមសិស្ស | រៀនតាមមេរៀនចាក់បង្ហាញតាមក្រោយ | រៀនតាមមេរៀនចាក់បង្ហាញភ្លាមៗ |
|---|---|---|
| សិស្សទាំងអស់ | 0.8% | 86.9% |
| សិស្សអាមេរិកាំង ខ្មៅ | 1.1% | 82.7% |
| សិស្សអាស៊ី | 0.5% | 91.5% |
| សិស្ស ខ្មែរ | 0.5% | 88.8% |
| សិស្ស ពីលីពីនណូ | 0.4% | 95.3% |
| សិស្ស ហ៊ីស្ប៉ានិក | 0.9% | 85.2% |
| សិស្សកោះ ប៉ាស៊ីហ្វិក | 0.9% | 83.6% |
| សិស្សអាមេរិកាំង ស | 0.6% | 93.4% |
| សិស្សរៀនភាសា អង់គ្លេស | 1.0% | 78.9% |
| សិស្ស EL + RFEP | 0.9% | 84.5% |
| សិស្សគ្មានផ្ទះរស់នៅ/សិស្សគេជ្រើសចិញ្ចឹម | 1.3% | 79.7% |
| សិស្ស SES បំផុត | 0.5% | 85.6% |
| សិស្សទទួលជំនួយ RSP | 0.5% | 83.7% |

ដើម្បីទទួលការយល់កាន់តែច្បាស់អំពីការរាប់ចំនួនវត្តមានប្រចាំថ្ងៃក្នុងពេលកំពុងរៀនពីចម្ងាយ គឺសូមបើកមើលនៅតាមសំណុំរឿង: Attendance During Distance Learning

| | |
|---|---|
| ចំនួន/ចំនួនភាគរយនៃសិស្ស ដែលតែងតែបំពេញកិច្ចការក្នុងពេលចាក់បង្ហាត់មេរៀនអោយឃើញភ្លាមៗ និង ការចាក់បង្ហាត់មេរៀនផ្ញើបង្ហាញតាមក្រោយ (ការបំបែកទៅតាមក្រុមដូចគ្នានៅផ្នែកខាងលើ) | គ្រូបង្រៀនរក្សាទុកសំណុំរឿងអំពីសិស្ស ដែលតែងតែបំពេញកិច្ចការនៅក្នុងពេលបង្ហាត់មេរៀនបង្ហាញភ្លាមៗ និង ការចាក់បង្ហាញមេរៀនតាមក្រោយ ។ សូមទាក់ទងទៅកាន់សាលារៀននៃសិស្សរបស់លោកអ្នកអំពីការរៀបចំបង្ហាត់មេរៀនយ៉ាងច្បាស់លាស់ណាមួយសម្រាប់សិស្សរបស់លោកអ្នក ។ |

<table>
<tr>
<td>តើមានសិស្សប៉ុន្មានភាគរយ ដែលតែងតែមិនអាចបើកចូលបាន ដោយមូលហេតុមានបញ្ហាផ្នែកបច្ចេកវិជ្ជា? (ការបំបែកទៅតាមក្រុមដូចគ្នានៅផ្នែកខាងលើ)</td>
<td>មកទល់ថ្ងៃទី5 ខែធ្នូ គឺសិស្សមានសមត្ថភាពប្រើខ្សែបណ្តាញកាន់តែច្រើននាក់ ។ មានប្រហែលចំនួន 0.51% នៃសិស្សថ្នាក់ TK រហូតដល់ទី 5 បានលើកបង្ហាញថា ពួកគេមានបញ្ហាបើកប្រើមិនចូល ហើយមានសិស្សមកពីក្រុមផ្សេងៗទៀតទាំងអស់បានបង្ហាញចំនួនចន្លោះ 0.2% និង 1.2% ។
<table>
<tr><td>ក្រុមសិស្ស</td><td>ចំនួនបង្ហាញបញ្ហានៅពេលបើកប្រើ</td></tr>
<tr><td>សិស្សអាមេរិកាំង ខ្មៅ</td><td>1.03%</td></tr>
<tr><td>សិស្សអាស៊ី</td><td>0.37%</td></tr>
<tr><td>សិស្ស ខ្មែរ</td><td>0.48%</td></tr>
<tr><td>សិស្ស ពីលីពីនណូ</td><td>0.69%</td></tr>
<tr><td>សិស្ស ហ៊ីស្ប៉ានិក</td><td>1.00%</td></tr>
<tr><td>សិស្សកោះ ប៉ាស៊ីហ្វិក</td><td>0.85%</td></tr>
<tr><td>សិស្សអាមេរិកាំង ស</td><td>0.36%</td></tr>
<tr><td>សិស្ស EL + RFEP</td><td>1.03%</td></tr>
<tr><td>សិស្សគ្មានផ្ទះរស់នៅ</td><td>1.28%</td></tr>
<tr><td>សិស្សគេជ្រើសចិញ្ចឹម</td><td>1.70%</td></tr>
<tr><td>សិស្ស SES បំផុត</td><td>1.07%</td></tr>
<tr><td>សិស្សទទួលជំនួយ RSP</td><td>1.20%</td></tr>
<tr><td>សិស្សទាំងអស់</td><td>0.85%</td></tr>
</table>
</td>
</tr>
<tr>
<td>តើបញ្ហាជាដដែលរបៀបណា ដែលក្រសួងអប់រំឌីស្ទ្រីគ ចំណាំឃើញអំពីសិស្សបិទការបង្ហាត់មេរៀនចោល បន្ទាប់ពីពេលទទួលអាថ្ងៃត្រង់ផុតទៅ?</td>
<td>មកទល់ថ្ងៃទី5 ខែធ្នូ គឺក្រសួងអប់រំ LBUSD បានចំណាំឃើញសិស្សមានបញ្ហាផ្នែកចូលរៀន ដែលកើនឡើងពីចំនួន 5.5% ទៅ 7.5% បន្ទាប់ពីសិស្សបានបិទចោលនៅពេលទទួលអាហារថ្ងៃត្រង់ ។</td>
</tr>
<tr>
<td>តើមធ្យោបាយដូចម្តេចត្រូវបានយកប្រើសម្រាប់ផ្តល់ជាពិន្ទុទៅកាន់សិស្ស ដែលមិនអាចចូលរៀនជាមួយកម្មវិធីបង្ហាត់ អនឡាញ បានដោយមូលហេតុទាក់ទងបញ្ហាផ្នែកបច្ចេកវិជ្ជា?</td>
<td>នៅតាមសំណុំរឿងដូចតទៅ គឺមានការពន្យល់អំពីក្បួន ដែលក្រសួងអប់រំ LBUSD ប្រើតាមសម្រាប់ផ្តល់ជាពិន្ទុទៅកាន់សិស្សក្នុងពេលកំពុងរៀនតាមរយៈ អនឡាញ<br>• ការផ្តល់ពិន្ទុជាសមភាព - ការលើកបង្ហាញពត៌មាននៅតាមទំព័រ<br>• ក្បួនប្រើការផ្តល់ជាពិន្ទុក្នុងក្រសួងអប់រំ LBUSD សម្រាប់ជាសមភាពក្នុងឆ្នាំសិក្សា 2020-2021</td>
</tr>
<tr>
<td>តើមានក្រុមគ្រួសារប៉ុន្មាននៅតែត្រូវការជំនួយផ្នែក 1) Chromebooks 2) អ៊ិនធើណែត ជាល្បឿនលឿន 3) ប្រដាប់ស្តាប់ពាក់ត្រចៀក? តើការចែកផ្តល់ គឺធ្វើតាមវិធីណា?</td>
<td>Chromebooks hot spots និង ប្រដាប់ប្រើសម្រាប់រៀនជាមួយមេរៀនទាំងអស់ត្រូវបានចែកផ្តល់ពីសាលារៀន ។ បើក្រុមគ្រួសារនៅតែខ្វះខាតជំនួយ សូមទាក់ទងសាលារៀននៃសិស្សរបស់ខ្លួន ។<br><br>មកទលថ្ងៃទី5 ខែធ្នូ:<br>• 6,223 Hotspots ត្រូវបានចែកទៅកាន់សិស្សក្នុងក្រសួងអប់រំ LBUSD<br>    ○ 4,040 នាក់មិនបានបើកប្រើក្នុងរយៈពេល 30 ថ្ងៃ<br>• 22,815 Chromebooks ត្រូវបានចែក<br>• សព្វថ្ងៃនេះ ការស្នើសុំទាំងអស់ទៅកាន់សាលារៀនអំពី Chromebooks និង Hotspots ត្រូវបានបំពេញតាម ហើយយើងនៅតែបន្តការចែក Hotspots ទៅតាមការស្នើសុំ ដែលបានទទួលជាបន្តបន្ទាប់<br>• សាលារៀនប្រហែលជាកំពុងតែស្នើសុំប្រដាប់ពាក់ស្តាប់ត្រចៀកមកពីឃ្លាំងនៃក្រសួងអប់រំ LBUSD<br>• ក្រសួងអប់រំ LBUSD មានចំនួន 45,000 គ្រឿងជា Chromebooks និង 2,100 គ្រឿងជា Hotspots សម្រាប់ចែកប្រើ</td>
</tr>
</table>

<table>
<tr>
<td>តើមានចំនួនប៉ុន្មានដង ដែលត្រូវបានទទួលតាមរយៈទូរស័ព្ទស្ដីអំពីការសុំជំនួយផ្នែកបច្ចេកវិជ្ជា? តើបញ្ហាលំបាកផ្នែកបច្ចេកវិជ្ជាត្រូវបានបង្ហាញប្រាប់ជាអ្វីខ្លះ ដែលធ្វើអោយប៉ះពាល់ដល់សមត្ថភាពនៃសិស្សបើកចូលទទួលការបង្ហាត់មេរៀន អនឡាញ?</td>
<td>តារាងផ្នែកខាងក្រោមបង្ហាញជាលទ្ធផលបានទទួលតាមរយៈទូរស័ព្ទ និង អ៊ីម៉ែល សម្រាប់សុំជាជំនួយបង្ហាញការប្រើបច្ចេកវិជ្ជាមកទល់ថ្ងៃទី5 ខែធ្នូ:
<table>
<tr><th>ខែ</th><th>ចំនួនលើកនៃទូរស័ព្ទហៅសុំជាជំនួយអំពីរបៀបប្រើ Chromebooks និង Hot spots</th><th>ចំនួនលើកនៃ អ៊ីម៉ែល ផ្ញើមកសុំជាជំនួយអំពីរបៀបប្រើ Canvas/Zoom</th></tr>
<tr><td>កញ្ញា</td><td>198</td><td>230</td></tr>
<tr><td>តុលា</td><td>55</td><td>80</td></tr>
<tr><td>វិច្ឆិកា</td><td>23</td><td>11</td></tr>
</table>
</td>
</tr>
<tr>
<td>តើមានមាតាបិតាប៉ុន្មាននាក់ត្រូវបានទទួលជំនួយផ្នែកបច្ចេកវិជ្ជា ជាម្នាក់ទល់ម្នាក់? តើមាតាបិតាគួរធ្វើដូចម្ដេច បើសិនជាសេវាកម្មទូរស័ព្ទ ប្រាប់បញ្ជូនពួកគាត់អោយទៅសុំជំនួយនៅតាម សាលារៀន ប៉ុន្តែ សាលារៀនប្រាប់មកវិញថា អោយពួកគាត់ទាក់ទងទៅកាន់សេវាកម្មទូរស័ព្ទវិញ?</td>
<td>ក្រសួងអប់រំ LBUSD បានរៀបចំជាក្រុមជាន់ថ្នាក់សម្រាប់ដោះស្រាយផ្ដល់ជំនួយបច្ចេកវិជ្ជាទៅកាន់ក្រុមគ្រួសារ ។ សាលារៀន គឺជាក្រុមជាន់ថ្នាក់មុនគេសម្រាប់ផ្ដល់ជាជំនួយ ហើយមាតាបិតាគួរតែធ្វើការទាក់ទងទៅកាន់សាលារៀននៃសិស្សរបស់ពួកគាត់ជាមុនសិនអំពីបញ្ហាអ្វីផ្សេងៗ ។ បើសិនជាសាលារៀនមិនអាចជួយបានទេ គឺបុគ្គលិកសាលារៀននឹងបញ្ជូនមាតាបិតាអោយទៅជួបក្រុមផ្សេងៗទៀត ដែលមានចំណេះយល់ដឹងច្រើនមកលើបញ្ហាត្រូវដោះស្រាយ ។</td>
</tr>
<tr>
<th colspan="2">ការទទួលជំនួយពន្យល់មេរៀន និង ជំនួយផ្សេងៗជាបន្ថែម</th>
</tr>
<tr>
<td>តើយើងអាចធ្វើការបញ្ជាក់ដូចម្ដេចសម្រាប់អោយដឹងថា សិស្ស ដែលត្រូវការជំនួយច្រើនជាងគេ គឺពិតជាបានទទួលការពន្យល់ផ្នែកមេរៀន និង ទទួលជាជំនួយបន្ថែមបានមែនក្នុងគ្រាកំពុងឆ្លងកាត់ជម្ងឺរាលដាល ដើម្បីកាត់បន្ថយការបាត់បង់ផ្នែករៀន?</td>
<td>គ្រូបង្រៀនបានប្រមូលទុកអំពីលទ្ធផលធ្វើការស្ទង់វាស់មើលមក (ទាំងផ្នែករៀន និង ផ្នែកអារម្មណ៍ និង ផ្លូវចិត្ត) ហើយកិច្ចប្រជុំក្នុងរដូវស្លឹកឈើធ្លាក់នៅខែវិច្ឆិកាត្រូវបានរៀបចំបើកជាមួយមាតាបិតា និង អ្នកគ្រប់គ្រងនៃសិស្ស ដើម្បីពិគ្រោះអំពីកិច្ចការធ្វើជាបន្តបន្ទាប់សម្រាប់នាំជាជំនួយមកលើភាពលូតលាស់ដល់សិស្ស ។</td>
</tr>
<tr>
<td>តើលទ្ធផលពីការស្ទង់វាស់បានបង្ហាញប្រាប់ជាអ្វីមកដល់ពេលនេះអំពីប្រភេទនៃក្រុមសិស្សទាំងឡាយណា ដែលរៀនចេះតែអន់ថយទៅឆ្ងាយជាងគេ?</td>
<td>គំរូប្រើតាមសម្រាប់កម្មវិធីនៅតាមសាលាបឋមសិក្សា ហៅ Elementary Distance Learning ត្រូវបានបង្កើតឡើងជាឱកាសសម្រាប់គ្រូបង្រៀនផ្ដល់កម្មវិធីអន្តរាគមន៍ទៅកាន់សិស្សជាក្រុមតូចៗ ឬម្នាក់ទល់ម្នាក់ ។</td>
</tr>
<tr>
<td>តើមានសិស្សប៉ុន្មាននាក់កំពុងទទួលជំនួយផ្នែកពន្យល់មេរៀនស្របតាមលក្ខណនិមួយៗដូចបានរៀបរាប់ក្នុងគម្រោង LCP? (ការបំបែកទៅតាមក្រុមដូចគ្នានៅផ្នែកខាងលើ)?</td>
<td>សាលារៀននិមួយៗរក្សាទុកសំណុំរឿងអំពីសេចក្ដីត្រូវការនៃសិស្សម្នាក់ៗសម្រាប់ផ្ដល់ជាកម្មវិធីអន្តរាគមន៍ ដែលមានដូចជាៈ ការជួយពន្យល់មេរៀន សាលារៀនថ្ងៃសៅរ៍ និង កម្មវិធីផ្សេងៗទៀត ។ សូមទាក់ទងសាលារៀននៃសិស្សរបស់លោកអ្នក បើសិនជាចង់ដឹងបន្ថែមអំពីកម្មវិធីអន្តរាគមន៍សម្រាប់សិស្ស ។<br><br>បន្ថែមទៅទៀត គឺមកទល់ថ្ងៃទី5 ខែធ្នូ មានកម្មវិធី WRAP សម្រាប់ជួយសិស្ស ដែលនៅក្នុងនោះ គឺមានគ្រូជំនួយនឹងផ្ដល់ជាៈ<br><br>កម្មវិធីអន្តរាគមន៍បន្ថែម<br>កម្មវិធី WRAP ជាកម្មវិធីទទួលសិស្ស បន្ទាប់ម៉ោងចេញពីរៀន</td>
</tr>
</table>

| | |
|---|---|
| | • នៅតាមសាលារៀន 16 កន្លែង ដែលមានកម្មវិធី WRAP គឺមានគ្រូជំនួយសម្រាប់ធ្វើការជួយពន្យល់មេរៀនទៅកាន់សិស្សប្រហែលចំនួន 291 នាក់ |
| តើការផ្តល់អន្តរាគមន៍សម្រាប់កម្មវិធីពន្យល់មេរៀនជារបៀបណា ដែលមានសម្រាប់ជួយសិស្សត្រូវការជំនួយពិសេស? តើត្រូវធ្វើស្របលក្ខណអ្វីខ្លះ ទើបអាចទទួលជំនួយបាន? | **<u>កម្មវិធីអន្តរាគមន៍នៅតាមសាលាបឋមសិក្សា:</u>**<br>• គ្រូបង្រៀនទទួលបន្ទុកពិសេស (TOSA) បានផ្តល់កម្មវិធីអន្តរាគមន៍ទៅកាន់សិស្សជាក្រុមតូចៗ និង ម្នាក់ទល់ម្នាក់ក្នុងត្រីមាសនៃរដូវស្លឹកឈើធ្លាក់ ។<br>• សាលារៀន Title I នឹងផ្តល់កម្មវិធីពន្យល់មេរៀននៅមុន និង បន្ទាប់ម៉ោងចេញពីរៀន និង ឬ សាលារៀនថ្ងៃសៅរ៍ក្នុងរដូវរងា (ខែមករា-ខែកុម្ភៈ) និង រដូវផ្ការីក (ខែមិនា-ខែឧសភា) សម្រាប់សិស្សថ្នាក់ទី 1-5 ទាំងឡាយណា ដែលនៅរៀនខ្សោយជាងគេ ។ |
| | **<u>កម្មវិធីអន្តរាគមន៍នៅតាមសាលាមធ្យមសិក្សា និង K-8:</u>**<br>**Tier 1:**<br>• មេរៀនចាក់បង្ហាត់ភ្លាមៗ ដែលមានភាពសំខាន់ច្បាស់លាស់<br>• ថ្នាក់ផ្តល់កម្មវិធីអន្តរាគមន៍ជាមួយចំណែកនៅក្នុងពេលរៀន<br>    ○ 83% នៃសាលារៀន MS/K8 ផ្តល់ជាថ្នាក់បង្ហាត់ CCR ភាសា អង់គ្លេស គណិតសាស្ត្រ និង សរសេរ<br>• ការផ្តល់ពិន្ទុ: 50% នៃគ្រូបង្រៀន គឺប្រើការផ្តល់ពិន្ទុជា scaled grading នៅតាមសាលាមធ្យមសិក្សា (6 កន្លែង គឺមានលើសជាង 80%)<br>**Tier 2/3:**<br>• កិច្ចការរៀនក្នុងថ្នាក់ជាក្រុមតូចៗជាមួយគ្រូបង្រៀន: 21 សាលារៀន<br>• កិច្ចការរៀនក្នុងថ្នាក់ជាក្រុមតូចៗជាមួយគ្រូ TOSA: 10 សាលារៀន<br>• កម្មវិធីពន្យល់មេរៀននៅមុន និង បន្ទាប់ម៉ោងចេញពីរៀន: 12 សាលារៀន<br>• កម្មវិធីពន្យល់មេរៀនក្នុងម៉ោងទទួលអាហារថ្ងៃត្រង់: 4 សាលារៀន<br>• វេនថ្នាក់ Zero សម្រាប់សិស្សថ្មី: 5 ចំណែកនៅតាម 8 សាលារៀន |
| | **<u>កម្មវិធីអន្តរាគមន៍នៅតាមវិទ្យាល័យ:</u>**<br>• អ្នកផ្តល់ឱវាទ គ្រូបង្រៀន និង នាយកសាលាបន្តការសួរសុខទុក្ខសិស្សដល់ផ្ទះ<br>• គ្រូបង្រៀនទុកពេលសម្រាប់ជួបសិស្សក្នុងម៉ោងប្រជុំ ម៉ោងអាហារថ្ងៃត្រង់ មុនម៉ោងចូលរៀន និង បន្ទាប់ម៉ោងចេញពីរៀន<br>• កម្មវិធីអន្តរាគមន៍សម្រាប់សិស្ស EL និង SPED បន្ទាប់ពេលចេញពីរៀន<br>• មេរៀន Urban Math Collaborative នៅតាមសាលារៀន បី កន្លែង<br>• កម្មវិធីអន្តរាគមន៍/ជំនួយ ហូមវើក ដែលផ្តល់ឡើងដោយគ្រូបង្រៀន និង សិស្ស<br>• នៅចុងត្រីមាស គឺបង្កើនជាជំនួយផ្សេងៗសម្រាប់ជួយទៅកាន់សិស្សកំពុងទទួលពិន្ទុ D/F |
| | **<u>កម្មវិធីអន្តរាគមន៍ផ្សេងៗជាបន្ថែម</u>**:<br>WRAP ជាកម្មវិធីទទួលសិស្ស បន្ទាប់ម៉ោងចេញពីរៀន<br>• WRAP មាននៅតាមសាលារៀន 56 កន្លែង ដែលមានសិស្ស 1,124 នាក់ កំពុងទទួលជំនួយផ្នែករៀនជាបន្ថែមតាមរយៈ អនឡាញ ដែលរាប់បញ្ចូលផងទាំងជំនួយធ្វើ ហូមវើក<br>• ក្នុងចំណោម 56 គឺ 16 កន្លែងមាននិស្សិតមហាវិទ្យាល័យធ្វើការជាគ្រូជំនួយសម្រាប់ពន្យល់មេរៀនទៅកាន់សិស្សចំនួន 291 នាក់ |

<table>
<tr><td></td><td>
<table>
<tr><th colspan="4">WRAP Sites offering Tutoring</th></tr>
<tr><th colspan="2">Elementary</th><th colspan="2">Secondary</th></tr>
<tr><td>Birney</td><td>Roosevelt</td><td>Cabrillo</td><td>Hoover</td></tr>
<tr><td>Bixby</td><td>Smith</td><td>Franklin</td><td>Jefferson</td></tr>
<tr><td>Lincoln</td><td>Stevenson</td><td>Gompers</td><td>Keller</td></tr>
<tr><td>Madison</td><td>Whittier</td><td>Hamilton</td><td>Stevens</td></tr>
</table>
</td></tr>
<tr><td>តើមាតាបិតាអាចសុំជំនួយពន្យល់មេរៀនបានតាមវិធីណាក្នុងឆ្នាំនេះ បើសិនជាពួកគេមិនទាន់បានប្រុងទុកសុំនៅឡើយ?</td><td>សូមទាក់ទងសាលារៀននៃសិស្សរបស់លោកអ្នក បើសិនជាលោកអ្នកចង់ដឹងបន្ថែមអំពីកម្មវិធីអន្តរាគមន៍ ដែលរាប់ទាំងកម្មវិធីពន្យល់មេរៀន និង សាលារៀនថ្ងៃសៅរ៍ផង ។<br><br>កម្មវិធីអន្តរាគមន៍បន្ថែម<br>WRAP ជាកម្មវិធីទទួលសិស្ស បន្ទាប់ម៉ោងចេញពីរៀន ។ មាតាបិតាអាចចុះឈ្មោះ អានឡាញ បានសម្រាប់ផ្ញើសិស្សក្នុងកម្មវិធី WRAP ដោយចុចយក:<br>https://www.lbschools.net/Departments/WRAP/virtual-wrap-2020-21.cfm<br><br>បើសិនជាមានសំនួរផ្សេងៗ គឺសូមទាក់ទងអ្នកគ្រប់គ្រងកម្មវិធី WRAP នៅតាមសាលារៀននៃសិស្សរបស់លោកអ្នក ឬ បើកមើលនៅតាម:<br>https://www.lbschools.net/Departments/WRAP/sites.cfm</td></tr>
<tr><th colspan="2">ការទទួលជំនួយអប់រំផ្នែកអារម្មណ៍</th></tr>
<tr><td>តើក្រសួងអប់រំ LBUSD អាចជួយសិស្ស និង ក្រុមគ្រួសារបានតាមវិធីណាសម្រាប់ផ្តល់ជាជំនួយអប់រំផ្នែកអារម្មណ៍ក្នុងគ្រាបង្កើនបញ្ហាភិតភ័យចាប់តាំងពីសាលារៀនបានបិទ ដោយមូលហេតុជម្ងឺ កូវីដ - COVID?</td><td>នៅពេលកំពុងរៀនពីចម្ងាយ គឺមណ្ឌលអប់រំ ហៅ Family Resource Center (FRC) មានបុគ្គលិកធ្វើការផ្តល់ជាជំនួយតាមរយៈ អនឡាញ និង ទូរស័ព្ទ ។ សិស្ស និង ក្រុមគ្រួសារ ដែលបានចុះឈ្មោះ គឺនឹងមានសិទ្ធិទទួលជំនួយផ្សេងៗ ។ សូមបើកមើលនៅតាម:<br>https://www.lbschools.net/Departments/Student_Support_Services/frc.cfm<br><br>ចំពោះសិស្ស និង ក្រុមគ្រួសារ ដែលគ្មានឈ្មោះក្នុងមណ្ឌល FRC គឺអាចសុំជំនួយអប់រំផ្នែកផ្លូវចិត្ត និង អារម្មណ៍បាននៅតាមគេហទំព័រនៃក្រសួងអប់រំ LBUSD ដូចតទៅ:<br>https:www.lbschools.net/Departments/Schoool_Support_Services/s-e-b-support.cfm</td></tr>
<tr><td>តើសាលារៀនបានធ្វើការស្ទង់វាស់តាមវិធីណាអំពីមធ្យោបាយ ដែលគ្រូបង្រៀនបង្កើតជាភាពកក់ក្តៅទៅកាន់សិស្សតាមរយៈការបង្ហាត់មេរៀន អនឡាញ?</td><td>គ្រូបង្រៀនទទួលការឃ្លាំមើលពីនាយកសាលា ឬ អនុនាយកសាលា ។ ពួកគាត់ទាំង ពីរ ធ្វើការបើកមើល បន្ទប់រៀន Canvas classrooms ជាញឹកញាប់ ហើយបានលើកបង្ហាញអំពីការយល់ឃើញរបស់ពួកគាត់ទៅកាន់គ្រូបង្រៀន ។ បន្ថែម គឺនៅតាមថ្នាក់ ក៏មានការចូលពិនិត្យដោយបុគ្គលិកការិយាល័យថ្នាក់លើផងដែរ ។ បើសិនជាលោកអ្នកមានបញ្ហាខ្វល់ខ្វាយអ្វី សូមទាក់ទងទៅកាន់គ្រូបង្រៀននៃសិស្សរបស់លោកអ្នកជាមុនសិន ហើយបន្ទាប់ទៅ ទើបទាក់ទងទោកាន់នាយកសាលា ។</td></tr>
<tr><td>បង្ហាញការរៀបរាប់អំពីមុខងារនៃអ្នកផ្តល់ឱវាទ សូស្ហាល់ វើគ័រ គ្រូចិត្តសាស្ត្រ និង អ្នកគ្រូពេទ្យក្នុងគ្រាបង្ហាត់មេរៀនពីចម្ងាយ និង តើពួកគេបំពេញមុខងាររៀងៗខ្លួនពីចម្ងាយតាមវិធីណា ។ តើពួកគេទទួលមុខងារធ្ងន់ធ្ងរដល់កម្រិតណា?</td><td><ul><li><u>សូស្ហាល់ វើគ័រ</u> - ជួយសិស្សអោយមានគ្រឿងបច្ចេកវិជ្ជាប្រើយ៉ាងត្រឹមត្រូវ - បំពេញកិច្ចការជាមួយបុគ្គលិកសាលារៀន និង ក្រុមគ្រួសារសម្រាប់ដោះស្រាយអំពីបញ្ហាផ្សេងៗប៉ះពាល់មកលើវត្តមានប្រចាំថ្ងៃនៃសិស្ស និង កម្មវិធីរៀនពីចម្ងាយ - សួរសុខទុក្ខដល់ផ្ទះទៅកាន់ក្រុមគ្រួសារណា ដែលពិបាកជួប ដើម្បីពិគ្រោះអំពីវត្តមានប្រចាំថ្ងៃ - បញ្ជូនក្រុមគ្រួសារអោយទៅទទួលជំនួយ (ដូចជា: អាហារ ការអប់រំផ្នែកអារម្មណ៍ និង ជំនួយហូមវើក ជាដើម) ជម្រាប់ជូនបុគ្គលិក LBUSD អំពីជំនួយថ្មីៗទើបតែមាន - ជម្រុញសិស្សដែលមនុស្សផ្សេងបានជ្រើសចិញ្ចឹមអោយចុះឈ្មោះទទួលជំនួយរៀនពីក្រសួងអប់រំ LACOE តាមកម្មវិធី អនឡាញ - បំពេញកិច្ចការជាមួយក្រសួង DCFS និង ជម្រកសម្រាប់សិស្សគ្មានផ្ទះរស់នៅ ដើម្បីផ្តល់ជាជំនួយដូចជា: កម្មវិធីរៀន អនឡាញ សំលៀក</li></ul></td></tr>
</table>

| | |
|---|---|
| | បំពាក់ ប្រដាប់ប្រើសម្រាប់ការរៀន និង លុយជា gift cards សម្រាប់ចំណាយតាមអ្វីចាំបាច់<br>• **អ្នកផ្តល់ឱវាទ** - រៀបជាមេរៀនសម្រាប់បង្ហាត់ទៅលើការអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្ត - ចូលរួមក្នុងកិច្ចប្រជុំ IEP 504 និង SST - ធ្វើការស្ទង់វាស់មើលក្នុងគ្រាមានវិបត្តិ - ទៅពិនិត្យសុខទុក្ខដល់ផ្ទះ - ឃ្លាំមើលវត្តមានប្រចាំថ្ងៃ - ផ្តល់កម្មវិធីអន្តរាគមន៍ទៅកាន់សិស្សកំពុងមានបញ្ហា - ជួបប្រជុំជាមួយមាតាបិតា និង តាមដានមើលអំពីពិន្ទុរៀនរបស់សិស្ស - ជួយបំពេញក្រដាស FAFSA សម្រាប់ចូលរៀននៅតាមមហាវិទ្យាល័យ - ផ្តល់ជំនួយទូទៅ និង បញ្ជូនសិស្ស និង ក្រុមគ្រួសារអោយទៅទទួលយកជំនួយផ្សេងៗក្នុងសហគមន៍<br>• **អ្នកគ្រូពេទ្យ** - ធ្វើការស្ទង់វាស់ផ្នែកសុខភាព (ជួបផ្ទាល់ និង សើរើសំណុំរឿង) សម្រាប់ IEP និង រៀបចំកិច្ចប្រជុំ - ផ្តល់ជំនួយទៅកាន់ 504 Plan - ធ្វើការពិនិត្យសំណុំរឿងចាក់ថ្នាំ និង បញ្ជូនអោយទៅចាក់ថ្នាំ បើសិនចាំបាច់ - ធ្វើការពិនិត្យតាមដានអំពីសិស្ស ដែលមានបញ្ហាសុខភាពច្រើន - ជួយស្របតាមបញ្ហាផ្សេងៗទាក់ទង COVID នៅក្នុងសាលា<br>• **គ្រូចិត្តសាស្រ្ត** - ធ្វើការស្ទង់វាស់មកលើកម្មវិធីអប់រំពិសេស - ចូលរួមកិច្ចប្រជុំ IEP & SST តាមរយៈ Zoom - ទៅពិនិត្យដល់ផ្ទះ និង ផ្តល់ជាជំនួយអប់រំក្នុងគ្រាមានវិបត្តិ បើសិនចាំបាច់ |
| **មណ្ឌលផ្តល់ជំនួយទូទៅសម្រាប់ក្រុមគ្រួសារ - Family Resource Centers (FRC)** | |
| តើនរណាជាអ្នកសម្រេចអំពីសិស្ស ឬ ក្រុមគ្រួសារ ដែលគួរទទួលជំនួយពីបុគ្គលិកសាលារៀន មណ្ឌល FRC ឬ បញ្ជូនអោយទៅទទួលជំនួយនៅតាមក្រសួងផ្សេងៗសម្រាប់ការអប់រំផ្នែកអារម្មណ៍? | • បុគ្គលណាម្នាក់ក៏បានដែរ គឺអាចបញ្ជូនសិស្សអោយទៅទទួលជំនួយបាន<br>• សិស្សខ្លួនគេផ្ទាល់ បើសិនជាមានអាយុ 12 ឆ្នាំ ឬ លើស (យោងតាមច្បាប់ Family Code § 6924 ដែលបញ្ជាក់ថា សិស្សអាយុ 12 ឬ លើស គឺអាចទទួលជំនួយអប់រំផ្នែកអារម្មណ៍ ដោយខ្លួនគេបាន).<br>• មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស ឬ សមាជិកក្នុងសហគមន៍ គឺអាចបញ្ជូនសិស្សអោយទៅទទួលជំនួយអប់រំបាន<br>• បុគ្គលិកនៃមណ្ឌល FRC ដែលបានទទួលចំណេះផ្នែកស្ទង់វាស់ MTSS (ត្រូវយល់ដឹងអំពីកម្រិតនៃជំនួយ ដែលត្រូវចែកផ្តល់) បើសិនជាសិស្សមានលក្ខណស្របតាមការទទួលជំនួយពីមណ្ឌល FRC គឺមានន័យថា អាចបើកសំណុំរឿងចាត់ចែងបាន បើសិនជាសិស្សត្រូវការជំនួយពីជាន់ថ្នាក់ tier 1 (សូមអានត្រឡប់ទៅវិញអំពីអ្នកផ្តល់ឱវាទ) ឬ ជំនួយពីជាន់ថ្នាក់ tier 3 (សូមអានត្រឡប់ទៅវិញអំពី SMBH collaborative) |
| តើមានសិស្សប៉ុន្មាននាក់ត្រូវបានបញ្ជូនអោយទៅទទួលជំនួយនៅតាមមណ្ឌល FRC នៃក្រសួងអប់រំ LBUSD? | មកទល់ថ្ងៃទី5 ខែធ្នូ 2018-19 **(625)**; 2019-20 **(611)** និង 2020-21 **(197) = (1,433)** |
| តើមានសិស្សប៉ុន្មាននាក់ត្រូវបានទទួលជំនួយអប់រំនៅក្នុងមណ្ឌល FRC ក្នុងឆ្នាំនេះ (ការបំបែកទៅតាមក្រុមដូចគ្នានៅផ្នែកខាងលើ)? | មកទល់ថ្ងៃទី5 ខែធ្នូ 2020 (61)<br>• មានសិស្ស 248 នាក់ត្រូវទទួលការបញ្ជូន<br>• មានសិស្ស 80 នាក់កំពុងទទួលជំនួយអប់រំពីបុគ្គលិកប្រចាំមណ្ឌល<br>• មានមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស 14 នាក់បានប្រកែកមិនព្រមទទួលជំនួយ<br>• មានសិស្ស 23 នាក់ត្រូវបានបញ្ជូនអោយទៅទទួលជំនួយនៅតាមក្រសួង SBMH ឬ ក្រសួងផ្សេងៗក្នុងសហគមន៍<br>• មាន 91 នាក់មិនទាន់ដឹងច្បាស់នៅឡើយ ដោយត្រូវការហត្ថលេខាពីមាតាបិតា ឬ អ្នកគ្រប់គ្រងនៃសិស្ស<br>• មានមាតាបិតា/អ្នកគ្រកប់គ្រងនៃសិស្ស 306 នាក់បានចូលរួមក្នុងក្រុមមាតាបិតានៅឆ្នាំនេះ |

| | |
|---|---|
| | • មានចំនួន 22 ម៉ោងត្រូវបានរក្សាទុកសម្រាប់ជួយហ្វឹកហ្វឺនទៅកាន់មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស<br>• មានសិស្ស 210 នាក់បានទទួលលទ្ធផលល្អមកពីការលើកពន្យល់អំពីរបៀបដោះស្រាយទឹកចិត្ត |
| តើមាតាបិតាអាចធ្វើការបញ្ជូនសិស្សរបស់ពួកគាត់អោយទៅទទួលជំនួយអប់រំនៅមណ្ឌល FRC តាមវិធីណា? | មាតាបិតាអាចបំពេញក្រដាស អនឡាញ ទាក់ទងអ្នកផ្តល់ឱវាទនៅតាមសាលារៀននៃសិស្ស ឬ ទាក់ទងផ្ទាល់ទៅកាន់បុគ្គលិកប្រចាំមណ្ឌល FRC ។ |
| តើត្រូវមានស្របតាមលក្ខណអ្វីខ្លះ ទើបអាចទទួលជំនួយពីមណ្ឌល FRC បាន? | សិស្សណាក៏ដោយ ដែលត្រូវការជំនួយរយៈពេលខ្លីអំពីការអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្ត ដែលស្របតាមជំនួយផ្តល់ដោយអ្នកផ្តល់ឱវាទ និង គ្រូចិត្តសាស្ត្រប្រចាំក្រសួងអប់រំ LBUSD ។ ក្រុមគ្រួសាររបស់សិស្សផងដែរ គឺអាចទទួលជំនួយបានពីសហគមន៍ ដូចជា:<br>• អាហារ/សំលៀកបំពាក់<br>• ជំនួយអប់រំផ្នែកផ្លូវចិត្ត<br>• កម្មវិធីទូទៅសម្រាប់ក្រុមគ្រួសារ<br>• Medi-Cal សម្រាប់អ្នកមានប្រាក់ខែទាប/គ្មានសមត្ថភាពបង់<br>• ជំនួយពិនិត្យសុខភាព<br>• ព័ត៌មានអំពីច្បាប់អន្តោប្រវេសន៍<br>បើសិនជាចង់ជ្រាបបន្ថែម សូមទាក់ទង:<br>***https://www.lbschools.net/Departments/Student_Support_Services/frc.cfm*** |
| **សហការណ៍សាលារៀនសម្រាប់ជំនួយអប់រំផ្នែកអារម្មណ៍-School-based Mental Health Collaborative (SBMH)** | |
| តើមានសិស្សប៉ុន្មាននាក់ត្រូវបានបញ្ជូនអោយទៅទទួលជំនួយជាមួយក្រសួងផ្សេងៗ ដែលធ្វើសហការណ៍ជាមួយសាលារៀន? | មកទល់ថ្ងៃទី5 ខែធ្នូ<br>• បញ្ជូនទៅកាន់ផ្ទាល់ពីមណ្ឌល FRC: 2018-19 **(574)**; 2019-20 **(594) = (1,168)**<br>• ទូទាំងក្រសួងអប់រំ ឪស្រ្ទីគ: 2018-19 **(1,339)**; 2019-20 **(1,318) = (2,657)** |
| តើមានសិស្សប៉ុន្មាននាក់ត្រូវបានទទួលជំនួយអប់រំផ្នែកអារម្មណ៍មកពីក្រសួងផ្សេងៗ ដែលធ្វើសហការណ៍ជាមួយសាលារៀន (ការបំបែកទៅតាមក្រុមដូចគ្នានៅផ្នែកខាងលើ)? | មកទល់ថ្ងៃទី5 ខែធ្នូ<br>• មណ្ឌល FRC: 2018-19 **(399)**; 2019-20 **(412) = (811)**<br>• ទូទាំងក្រសួងអប់រំ ឪស្រ្ទីគ: 2018-19 **(914)**; 2019-20 **(897)** = **(1,811)** |
| តើជំនួយអប់រំជាប្រភេទណា ដែលមានផ្តល់មកពីក្រសួងផ្សេងៗ ដែលធ្វើសហការណ៍ជាមួយសាលារៀន? | • អស់រយៈពេលជាង ដប់ ឆ្នាំមកហើយ ក្រសួងអប់រំ LBUSD បានបំពេញកិច្ចការជាមួយក្រសួង Department of Mental Health និង ក្រសួង ប្រាំមួយ កន្លែងទៀតសម្រាប់នាំមកជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តជួយសាលារៀន ដើម្បីផ្តល់បានទៅកាន់សិស្ស និង ក្រុមគ្រួសារទាំងឡាយណា ដែលកំពុងមានបញ្ហាស្មុគស្មាញ និង ត្រូវការជំនួយ ។<br>• មកទល់ថ្ងៃនេះ គឺមានសាលារៀនប្រហែល 60 កន្លែងក្នុងក្រសួងអប់រំ LBUSD ដែលកំពុងតែបានទទួលជំនួយមកពីក្រសួងជាដៃគូណាមួយរបស់យើងនៅតាមសហគមន៍ ។ |
| តើមាតាបិតាអាចធ្វើការបញ្ជូនសិស្សរបស់ពួកគាត់អោយទៅទទួលជំនួយនៅតាមក្រសួងផ្សេងៗ ដែលធ្វើសហការណ៍ជាមួយសាលារៀនតាមវិធីណា? | • មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស គឺអាចស្នើសុំការបញ្ជូនអោយទៅទទួលជំនួយអប់រំនៅតាមក្រសួង SBMH បាន ដោយធ្វើការជួបពិគ្រោះជាមួយអ្នកផ្តល់ឱវាទនៅតាមសាលារៀននៃសិស្សរបស់ពួកគាត់ ។ |

<table>
<tr><th colspan="2">ទំនាក់ទំនងជាមួយមាតាបិតា</th></tr>
<tr><td>តើមាតាបិតាអាចបង្កើនទំនាក់ទំនងយ៉ាងប្រសប់តាមវិធីណាក្នុងនាមជាដៃគូជាមួយកម្មវិធីនៃសិស្សរបស់ពួកគាត់ និង ក្នុងការជួយសម្រេចមកលើកិច្ចការនៅតាមសាលារៀន និង ក្រសួងអប់រំ ឌីស្រ្ទីគ?</td>
<td>ទំនាក់ទំនងយ៉ាងប្រសប់ គឺចាប់ផ្តើមឡើងនៅតាមសាលារៀន ។ មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សគួរទាក់ទងផ្ទាល់ទៅកាន់គ្រូបង្រៀននៃសិស្សរបស់ពួកគាត់ ដើម្បីសួរអំពីអ្វីអាចជួយមកបានសម្រាប់សេចក្តីត្រូវការតាមផ្នែករៀន ។ អ្នកផ្តល់ឱវាទ និង នាយកសាលាក៏មានមុខងារសំខាន់ដែរក្នុងការបង្កើនដៃគូរវាងសាលារៀន និង ផ្ទះ ។ ការិយាល័យ Parent University អាចផ្តល់ជាជំនួយជូនក្រុមគ្រួសារបានសម្រាប់ប្រើជាដៃគូ - សូមអានបន្តនៅផ្នែកខាងក្រោម ។<br><br>បើជជែកអំពីការជួយធ្វើការសម្រេចវិញ គឺមាតាបិតា និង អ្នកគ្រប់គ្រងនៃសិស្សក៏គួរចាប់ផ្តើមធ្វើនៅតាមសាលារៀនផងដែរ ។ ក្រុមប្រឹក្សាប្រចាំសាលារៀន ហៅ School site council (SSC) មានមុខងារក្តោបក្តាប់មកលើថវិការសម្រាប់ប្រើដោះស្រាយតាមសេចក្តីត្រូវការពិសេសរបស់សិស្ស ។ មាតាបិតា និង អ្នកគ្រប់គ្រងនៃសិស្សគួរឆែកមើលនៅតាម គេហទំព័រសាលារៀន ឬ ទាក់ទងផ្ទាល់ទៅកាន់សាលារៀន ដើម្បីសុំសួរអំពីពេលប្រជុំ SSC ដែលផ្តល់ឱកាសសម្រាប់ដាក់ពាក្យផ្តាំផ្ញើ ។ បើសិនជាមានចិត្តចូលរួមជាមួយ SSC (ឬ អ្វីផ្សេង ដូចជា: ក្រុមប្រឹក្សាផ្តល់ឱវាទសម្រាប់សិស្សរៀនភាសាអង់គ្លេស) គឺសូមទាក់ទងទៅកាន់សាលារៀន ។ ដូចគ្នាដែរ គឺមានការចូលបំពេញកិច្ចការជាមួយក្រុមរួមចំណែកផ្សេងៗនៅតាមកម្រិត ឌីស្រ្ទីគ ដូចជា: ក្រុមប្រឹក្សាផ្តល់ឱវាទកម្រិត ឌីស្រ្ទីគ សម្រាប់សិស្សរៀនភាសា អង់គ្លេស និង ក្រុមប្រឹក្សាផ្តល់ឱវាទរវាងក្រសួងអប់រំ ឌីស្រ្ទីគ និង សហគមន៍ ជាដើម ដែលត្រូវបានទទួលការតែងតាំងឡើងជាអ្នកតំណាងដោយនាយកសាលារៀន ។<br><br>ព័ត៌មានបន្ថែមស្តីអំពី “មធ្យោបាយសម្រាប់ចូលរួមធ្វើការសម្រេចជាមួយសាលារៀន និង ក្រសួងអប់រំ ឌីស្រ្ទីគ” គឺមានលើកបង្ហាញក្នុងកិច្ចប្រជុំសហគមន៍មួយ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី20 ខែតុលា ឆ្នាំ2018 និង មានជាភាសា អង់គ្លេស អេស្ប៉ាញ៉ូល និង ខ្មែរ ។</td></tr>
<tr><td>បង្ហាញការរៀបរាប់អំពីក្រុមរួមចំណែកនិមួយៗក្នុងក្រសួងអប់រំ LBUSD ដែលត្រូវបានទទួលការសុំពិគ្រោះជាមួយអំពីថវិការ និង មុខងារនៃក្រុមរួមចំណែកនិមួយៗក្នុងការជួយរៀបចំថវិការ ។ លើកផ្តល់ជា ថ្ងៃ ខែ ដែលក្រុមទាំងអស់បានជួបប្រជុំ និង ពន្យល់អំពីមធ្យោបាយដែលមាតាបិតាផ្សេងៗអាចចូលរួមជាមួយបាន ។</td>
<td>




ក្រុមប្រឹក្សាសម្រាប់មាតាបិតាប្រចាំក្រសួងអប់រំ ឌីស្រ្ទីគ គឺមានបង្ហាញជាពណ៌ ក្រហម ។ ថ្ងៃ ខែ សម្រាប់កិច្ចប្រជុំ គឺមានបង្ហាញនៅតាមការិយាល័យ *Parent University* ដោយពិនិត្យមើល: *bit.ly/parent_university*</td></tr>
</table>

| | |
|---|---|
| បង្ហាញការរៀបរាប់អំពីមុខងារនៃក្រុមប្រឹក្សាមាតាបិតានៅតាមសាលារៀន និង តើពួកគេមានចំណែកអ្វីខ្លះក្នុងការជួយគិតសម្រេចក្នុងគ្រាកំពុងរាលដាលជម្ងឺ និង មធ្យោបាយសម្រាប់មាតាបិតាអាចគិតសម្រេចបានផងនៅតាមកម្រិតក្រសួងអប់រំ ឌីស្រ្ទិគ ។ | <br>តារាងផ្នែកខាងលើ គឺបង្ហាញអំពីមុខងារនៃក្រុមប្រឹក្សានៅតាមសាលារៀន ដែលជួយបង្កើតជាគម្រោងតែមួយសម្រាប់លទ្ធផលជោគជ័យដល់សិស្សទាំងអស់ ។<br><br>ដំណើការរៀបចំក្រុមប្រឹក្សានិមួយៗ គឺនៅតែប្រើជារបៀបដដែលក្នុងគ្រារាលដាលជម្ងឺ ដោយជួបប្រជុំតាមរយៈ អនឡាញ ។ សម្រាប់ពត៌មានបន្ថែម សូមបើកមើលនៅតាមៈ<br>*https://www.lbschools.net/Departments/Parent_U/school_site_council.cfm* |
| តើមាតាបិតាអាចទទួលជំនួយអំពីកម្មវិធីហ្វឹកហ្វឺនប្រើ Canvas និង កម្មវិធីរៀន អនឡាញ បានតាមវិធីណា? | ក្រសួងអប់រំ LBUSD បានរៀបចំជាជំនួយដូចតទៅសម្រាប់ជួយទៅកាន់មាតាបិតាអំពីរបៀបប្រើ Canvas និង អ្វីផ្សេងៗ<br>• ក្បួននៃនាំសម្រាប់មាតាបិតាប្រើ Canvas<br>• កម្មវិធីបង្ហាញមាតាបិតាអំពី Canvas 101<br>• ចំណេះចាំបាច់សម្រាប់មាតាបិតាបិតា<br>• ការលើកបង្ហាញជាបន្តបន្ទាប់អំពីរបៀបប្រើ Canvas<br>----------------------------------------------------------------------<br>• ក្រសួងអប់រំ LBUSD ផ្តល់កម្មវិធីហ្វឹកហ្វឺនជាញឹកញាប់ជូនមាតាបិតាអំពីសាច់រឿងល្អពិសេសច្រើនចំណែក ។ សូមបើកមើលអំពីថ្ងៃខែសម្រាប់កម្មវិធីនៅតាមការិយាល័យ Parent University និង ការចាក់បង្ហាញកម្មវិធីនៅតាម យូធូប ។ |